**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**
**នាយកដ្ឋានផែនការត្រួតពិនិត្យវាយតម្លៃនិងស្រាវជ្រាវ**

# កំណត់ហេតុ
# កិច្ចប្រជុំការងារបច្ចេកទេសប្រចាំសប្តាហ៍

**ថ្ងៃច័ន្ទទី២០ខែកក្កដាឆ្នាំ២០១៥នៅសាលប្រជុំអ.ជ.ប.ជ.អ**

## ១. សេចក្តីផ្តើម:

នៅវេលាម៉ោង៩:០០នាទីព្រឹកថ្ងៃ ច័ន្ទ ទី ២០ ខែ កក្កដា ឆ្នាំ២០១៥ អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ មានរៀបចំកិច្ចប្រជុំការងារបច្ចេកទេសប្រចាំសប្តាហ៍ ក្រោមការដឹកនាំកិច្ចប្រជុំដោយ ឯកឧត្តមវេជ្ជបណ្ឌិត **តៃង គន្ធី** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដោយមានការចូលរួមពី អគ្គលេខាធិការរង ប្រធាន និងអនុប្រធាននាយកដ្ឋាន សរុបទាំងអស់ចំនួន ២០រូប អវត្តមាន ០១រូប (មានភ្ជាប់ជូនបញ្ជីវត្តមានចូលរួម) ។

## ២. ប្រធានបទនៃកិច្ចប្រជុំ

- សកម្មភាពការងារតាមនាយកដ្ឋាននីមួយៗ
- ផ្សេងៗ
- ការបូកសរុប មតិណែនាំ របស់អគ្គលេខាធិការដ្ឋាន

## ៣. ដំណើរការនិងលទ្ធផលនៃកិច្ចប្រជុំ.

ជាកិច្ចចាប់ផ្តើមនៃអង្គប្រជុំ ឯកឧត្តមវេជ្ជ. **តៃង គន្ធី** អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ មានមតិស្វាគមន៍ចំពោះ ឯកឧត្តម លោក លោកស្រី អគ្គលេខាធិការរង ប្រធាន និងអនុប្រធាននាយកដ្ឋាន ដែលបានចូលរួមក្នុងកិច្ចប្រជុំនាព្រឹកនេះ ។

មុននិងអនុញ្ញាតឲ្យនាយកដ្ឋាននីមួយៗ ធ្វើសេចក្តីរាយការណ៍ពីការអនុវត្តសកម្មភាពឯកឧត្តមប្រធានអង្គប្រជុំបានពិនិត្យមើលឡើងវិញពីផែនការដែលបានដាក់កាលពីសប្តាហ៍មុន តើអនុវត្តបានអ្វីខ្លះដោយសារអ្វី និងធ្វើមិនបានដោយមូលហេតុអ្វី?

ជាបន្តតាមនាយកដ្ឋាននីមួយៗ បានធ្វើសេចក្តីរាយការណ៍ដូចខាងក្រោមៈ

## ៣.១. នាយកដ្ឋានទាក់ទង និងចលនាប្រភពធនធាន

**សកម្មភាពការងារដែលបានអនុវត្តសប្តាហ៍កន្លងមកៈ**

- បានចូលរួមកិច្ចប្រជុំជាមួយប្រតិភូ នៅថ្ងៃទី១២ កក្កដា ២០១៥
- បានធ្វើបទបង្ហាញ នៅខេត្តស្ទឹងត្រែង ទាក់ទងនិងគ្រឿងញៀន និងជម្ងឺអេដស៍
- GDJ នៅថ្ងៃទី ១០ កក្កដា ២០១៥ បានធ្វើការពិភាក្សាផងដែរសំរាប់ការរៀបចំកម្មវិធីសំរាប់ប្រជុំនៅថ្ងៃទី ៣ ខែសីហា ។ ម្យ៉ាងទៀតនៅក្នុងកិច្ចប្រជុំសមាជិកអង្គប្រជុំបានមានមន្ទិលសង្ស័យថាតើ GDJ នេះអាចមាននិរន្តរភាពឬយ៉ាងណាដែរ?
- បានចាត់មន្ត្រីចូលរួមកិច្ចប្រជុំ ធ្វើផែនការយុទ្ធសាស្ត្រជាតិលើកទី៤
- បានធ្វើបច្ចុប្បន្នភាពអង្គការក្រៅរដ្ឋាភិបាលដែលកំពុងអនុវត្តការងារអេដស៍បានចំនួន

**សកម្មភាពការ ងារដែលត្រូវអនុវត្តសប្តាហ៍បន្ទាប់ ៖**

- រៀបចំកិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេស NAA ថ្ងៃទី២៨ កក្កដា ២០១៥
- រៀបចំកិច្ចប្រជុំ GDJ នៅថ្ងៃទី ០៣ សីហា ២០១៥

**ឯឧ.អគ្គលេខាធិការបានណែនាំបន្ថែម ពីការងារដែលត្រូវធ្វើបន្តៈ**

✓ រៀបចំ សារសំរាប់បុណ្យអុំទូក និងទិវាអេដស៍

✓ ឯកភាពតាមលោកប្រធាននាយកដ្ឋានលើមធ្យោបាយសម្រាប់ចុះបេសកកម្មកុំប្រើរថយន្តឈ្នួល ចាប់ពីប្រធាននាយកដ្ឋាន បើដោះស្រាយមិនបានមិនចាំបាច់ចុះបេសកកម្មទេ

✓ សុំបញ្ចប់ការធ្វើបច្ចុប្បន្នភាពអង្គការក្រៅរដ្ឋាភិបាលដែលកំពុងអនុវត្តការងារអេដស៍នៅតាមខេត្ត និងរាជធានី ក្នុងសប្តាហ៍នេះ។

## ៣.២. នាយកដ្ឋាន បង្ការ ថែទាំ និង គាំទ្រ

**សកម្មភាពការ ងារដែលបានអនុវត្តក្នុងសប្តាហ៍កន្លងមកៈ**

- បានចូលរួមកិច្ចប្រជុំ ធ្វើផែនការយុទ្ធសាស្ត្រជាតិលើកទី៤ នៅថ្ងៃទី ១៦ កក្កដា ២០១៥

- បានធ្វើលិខិតដែលទាក់ទង និង ការងារធ្វើផែនការសុំអង្គរឲ្យអ្នកជម្ងឺអេដស៍ដាក់ជូនឯកឧត្តមប្រធាន អាជ្ញាធរ រួចហើយ ។
- រៀបចំកិច្ចប្រជុំលេខាធិការដ្ឋាន MSM និង ប្រុសស្អាត នៅថ្ងៃទី ១៧ កក្កដា ២០១៥
- បានប្រមូលទិន្នន័យទាក់ទងនិងក្រុម MARPs នៅខ្វះ២ខេត្តទៀតរតនគីរីនិងព្រះវិហា ដោយធ្វើការទំនាក់ទំនងគ្នាតាមទូរស័ព្ទ និង អ៊ីមែលមិនបាន ។ ចំពោះទិន្នន័យដែលទទួលបានមានទិន្នន័យខ្លះមិនអាចទទួលយកបានដូចនេះយើងត្រូវពិនិត្យឡើងវិញ។

**សកម្មភាពការ ងារដែលត្រូវអនុវត្តសប្តាហ៍បន្ទាប់ ៖**

- បន្តការងារប្រមូលទិន្នន័យដែលនៅសល់ពីសប្តាហ៍មុន
- បូកសរុបរបាយការប្រចាំខែ
- ពិនិត្យតាមដានការងារមូលនិធិសកលជាប្រចាំ
- បង្រៀនដល់ឃុំ/សង្កាត់ឲ្យចេះប្រើប្រាស់ទិន្នន័យ OVC នៅថ្ងៃទី៥, ៦ ខែសីហា ២០១៥

**ឯឧ.អគ្គលេខាធិការបានណែនាំពីការងារដែលត្រូវធ្វើបន្តៈ**

✓ រាល់ទិន្នន័យដែលប្រមូលបាន ត្រូវធ្វើសេចក្តីរាយជាអក្សរមិនចាំបាច់រង់ចាំទៀតទេ នៅសល់ប៉ុន្មានខេត្តទៀតត្រូវធ្វើចិខិតជាផ្លូវការផ្ញើតាមក្រោយទៀត និង រាល់ទិន្នន័យដែលប្រមូលបានត្រូវមានអ្វីជាសំអាង។

✓ រាល់កិច្ចការងារត្រូវអនុវត្តទៅតាមឋានានុក្រម

✓ ក្នុងករណីប្រធាននាយកដ្ឋានមិននៅត្រូវមានអ្នកណាម្នាក់ទទួលខុសត្រូវជំនួស

✓ លោកឌីត្រូវមានលិខិតអញ្ជើញពីស្ថាប័នទាក់ទងក្នុងការចុះបង្រៀនឃុំ/សង្កាត់

## ៣.៣ នាយកដ្ឋានផែនការត្រួតពិនិត្យ វាយតំលៃ និងស្រាវជ្រាវ

**សកម្មភាពការ ងារដែលបានអនុវត្តក្នុងសប្តាហ៍កន្លងមកៈ**

- បានបញ្ចប់ការកែសម្រួលផែនការយុទ្ធសាស្ត្រទី ៤ និងដាក់ជូនទៅឯកឧត្តមប្រធាន
- បានបញ្ចប់ និងបញ្ជូន PUDR NCHARDS
- បញ្ចប់របាយការប្រជុំលេខាធិការដ្ឋាន GDJ និងដាក់ជូនថ្នាក់ដឹកនាំនៅក្នុងសប្តាហ៍នេះ ។

- បានប្រជុំមន្ត្រីនាយកដ្ឋានដើម្បីពិនិត្យនិងកែសំរួលពីការងារទទួលខុសត្រូវរបស់មន្ត្រី និងរៀបចំយុទ្ធសាស្រ្ត តាមដាន វាយតម្លៃ ឲ្យស្របទៅនិងការងារមូលនិធិសកល សំរាប់ new funding model ។
- បានបញ្ជូនលិខិតជាផ្លូវការក្នុងការសុំរបាយការណ៍ត្រីមាសទី២ពីខេត្ត និង រាជធានីដោយមានភ្ជាប់គំរូរបាយការណ៍ទៅជាមួយ។
- រៀបចំបទបង្ហាញដល់ក្រុមបច្ចេកទេសពីរបាយការណ៍ GARPR

**ឯខ.អគ្គលេខាធិការបានណែនាំពីការងារដែលត្រូវធ្វើបន្តៈ**

- ចាត់តាំងមន្ត្រីទទួលការងារប្រមូល និងផ្សព្វផ្សាយព័ត៌មានថ្មីៗពាក់ព័ន្ធនិងជម្ងឺអេដស៍

## ៣.៤ នាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ

**សកម្មភាពការងារដែលបានអនុវត្តក្នុងសប្តាហ៍កន្លងមកៈ**

- ការរៀបចំកែសំរួលសមាសភាពសមាជិក TAB បានស្រាវជ្រាវរកឃើញឯកសារ ចំនួន ២ នៅខាងព្រឹទ្ធសភាមិនទាន់រកឃើញ ហើយយើងកំពុងរៀបចំគោលការណ៍ស្នើសុំ ។
- បានចាត់តាំងមន្ត្រីទទួលរបាយការណ៍បេសកកម្ម(មុនីរដ្ឋ) និងបានចែកជូនការណែនាំពីការបំពេញឯកសារបេសកកម្ម និងបានអនុវត្ត។
- បានរៀបចំបញ្ជីសារពើភ័ណ្ឌតាមនាយកដ្ឋានបំពេញ តែទទួលបានមកវិញតែមួយនាយកដ្ឋាន ។
- បានរៀបចំគណៈកម្មការបុណ្យអុំទូក និងទិវាអេដស៍ ២ធ្នូ
- ថវិកាបេសកកម្មទូទាត់ត្រង់ដើមឆ្នាំ ២០១៥ បានមកហើយ និង បើកជូននៅក្នុងសប្តាហ៍នេះ ។
- ថវិកាប្រជុំយេនឌ័រ និងប្រជុំនៅខេត្តកែបបានចូលមកដែរ

**សកម្មភាពការងារដែលត្រូវអនុវត្តសប្តាហ៍បន្ទាប់ៈ**

- របាយការណ៍ចំណាយថវិការទាំងមូល(ឆ្នាំ២០១៣, ២០១៤ និងឆមាសទី១ ២០១៥)

**ឯឧ.អគ្គលេខាធិការបានណែនាំពីការងារដែលត្រូវធ្វើបន្ត៖**

- ✓ បន្តការងាររៀបចំសមាសភាពសមាជិក TAB ដោយស្រាវជ្រាវរកឯកសាររបស់ជំទាវព្រឹទ្ធសភា បើរកមិនឃើញត្រូវធ្វើការទំនាក់ទំនងឡើងវិញ។
- ✓ រាល់លិខិតអញ្ជើញមកដល់ថ្ងៃនេះ ថ្ងៃស្អែក ចូលរួមមិនចាំបាច់ទៅទេ
- ✓ សម្រាប់យើងវិញរដ្ឋបាលត្រូវពិនិត្យនិងតាមដានឡើងវិញថាលិខិតអញ្ជើញបានទៅដល់សាមីខ្លួនហើយឬនៅ ពេលណា ?
- ✓ ប្រមូលសម្ភារៈដែលមិនអាចប្រើការបានចូលឃ្លាំង

## ៤. សំណូមពរ និងផ្សេងៗ

- លោកវេជ្ជ. **ស៊ឹម តមសាន** បានសុំណូមពរ លើមធ្យោបាយសម្រាប់ចុះបេសកកម្មកុំឲ្យចុះតាមរថយន្តឈ្នួលសុំមេត្តាឲ្យមានរថយន្តស្ថាប័នសម្រាប់ចុះចាប់ពីប្រធាននាយកដ្ឋាន ។
- ប្រធាននាយកដ្ឋានរដ្ឋបាលហិរញ្ញវត្ថុ សុំណូមពរសុំឲ្យធ្វើលិខិតដូរថ្ងៃប្រជុំ GDJ និង របាយការណ៍ TAB
- ឯឧ. **ឈឹម ឃិនដារ៉េត** សុំណូមឲ្យនាយកដ្ឋាន២ គឺរដ្ឋបាលហិរញ្ញវត្ថុ និង M&E ទៅធ្វើទំនាក់ទំនងជាមួយក្រសួងសុខាភិបាលពីបែបបទធ្វើរបាយការណ៍ឲ្យបានត្រឹមត្រូវ បើយើងមិនមានរបាយការណ៍លទ្ធផលទេអាចកាត់ថវិកាសំរាប់ឆ្នាំ២០១៦ ។ ម្យ៉ាងទៀតថវិកាអាចនៅសល់ច្រើន យើងអាចរៀបចំការប្រជុំពិនិត្យផែនការឡើងវិញទៅតាមផែនការរបស់យើងដែលបានលើកឡើង ។

## ៥. ការបូកសរុប និងមតិណែនាំរបស់ឯកឧត្តមអគ្គលេខាធិការដ្ឋាន

មុននិងបញ្ចប់ឯកឧត្តមប្រធានអង្គប្រជុំបានផ្តល់មតិណែនាំនិងអនុសាសន៍មួយចំនួនដូចខាងក្រោម:

- CRM
  - ធ្វើលិខិតកែសំរួលថ្ងៃប្រជុំ GDJ
  - កំណត់ថ្ងៃការធ្វើបច្ចុប្បន្នភាពអង្គការក្រៅរដ្ឋាភិបាលដែលកំពុងអនុវត្តការងារអេដស៍នៅតាមខេត្ត និងរាជធានី ក្នុងសប្តាហ៍នេះ
  - តាមដានការងារ NB ដែលត្រូវប្រជុំ

- ពិនិត្យមើលរបាយការណ៍ដែលនៅខ្វះចន្លោះត្រូវបំពេញឡើងវិញ
- រៀបចំ សារសំរាប់បុណ្យអុំទូក និងទិវាអេដស៍១ធ្នូ ឲ្យបានក្នុងសប្តាហ៍នេះ

o PCS
- កំណត់ថ្ងៃ បញ្ចប់ការធ្វើបច្ចុប្បន្នភាពព័ត៌មានថ្មីៗ និង OVC ឲ្យបានច្បាស់
- ធ្វើការទំនាក់ទំនងផ្ទាល់ជាមួយឯកឧត្តមអនុប្រធានទា ផលា

o M&E
- បន្តផែនការយុទ្ធសាស្ត្រទី ៥
- ការងារប្រមូល និងផ្សព្វផ្សាយព័ត៌មានថ្មីៗពាក់ព័ន្ធនិងជម្ងឺអេដស៍

o A/F
- បន្តការងាររៀបចំសមាសភាពសមាជិក TAB ដោយស្រាវជ្រាវរកឯកសាររបស់ជំទាវព្រឹទ្ធសភា បើរកមិនឃើញត្រូវធ្វើការទំនាក់ទំនងឡើងវិញ និង ធ្វើកំណត់បង្ហាញសុំលិខិតជំរាបជូនទៅសាម៉ីពក្រសួងដែលត្រូវផ្លាស់ប្តូរថាបានទទួលលិខិតហើយ និង ធ្វើការកែសម្រួលតាមក្រោយ។
- តាមដានការចែកនិងទទួលលិខិត
- ធ្វើលិខិតចាត់តាំងមន្ត្រីសំរាប់ទំនាក់ទំនងជាមួយក្រសួងសុខាភិបាល ។
- រដ្ឋបាលហិរញ្ញវត្ថុធ្វើបញ្ជីឈ្មោះអ្នកជំពាក់ឯកសារ

ជាការបញ្ចប់ឯកឧត្តមប្រធានអង្គប្រជុំបានអគុណដល់មន្ត្រីគ្រប់លំដាប់ថ្នាក់ដែលបានចូលរួមប្រជុំ និងខិតខំប្រឹងប្រែងធ្វើការងារកន្លងមករហូតទទួលបានជោគជ័យ ។

កិច្ចប្រជុំបានបញ្ចប់នៅវេលា ម៉ោង១១:១៥នាទីព្រឹក ថ្ងៃខែឆ្នាំដដែល ប្រកបដោយបរិយាកាសរីករាយនិងស្និទ្ធស្នាលជាទីបំផុត។

ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៥

មន្ត្រីទទួលបន្ទុក

**ឱសថ. ចេង ថា**

ប្រធាននាយកដ្ឋានផែនការ តាមដាន

វាយតម្លៃ និងស្រាវជ្រាវ

**វេជ្ជ.លី ចាន់វ៉ាវុធ**

បានឃើញនិងឯកភាព

អគ្គលេខាធិការ

**ឯកឧត្តមវេជ្ជ.តែងគន្ធី**